ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

Office of the Council of Ministers

ឆ្នាំទី២ (២០១៨)

# ព្រឹត្តិបត្រព័ត៌មាន

# មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់

# ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# (ម.ត.ឯ.ច.)








គេហទំព័រ៖ www.ldc-eccc.gov.kh

អ៊ីមែល៖ info@ldc-eccc.gov.kh

ទំព័រ ហ្វេសបុក៖ www.ldc-eccc.gov.kh

ទូរស័ព្ទ៖ +៨៥៥ ២៣ ២៣១ ២២១

ផ្លូវ១៩២៨ & ១១២៩ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

សូមថ្លែងអំណរគុណដល់រដ្ឋាភិបាលជប៉ុនដែលបានជួយគាំទ្រ និងឧបត្ថម្ភដល់ម.ត.ឯ.ច.

ការរក្សាកេរដំណែលរបស់ អ.វ.ត.ក. សម្រាប់ការពិត យុត្តិធម៌ និងការចងចាំ

# មាតិកា

*លេខទំព័រ*


- ◆ សេចក្តីផ្តើម........................................................................ ១
- ◆ សារជូនពរឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការកាន់តំណែងរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី........................................ ២
- ◆ វេទិកាស្តីពី ការវិវឌ្ឍន៍នីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងសំណងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០២........................................ ៣
- ◆ ទស្សនកិច្ចសិក្សារបស់ភ្ញៀវជាតិ និងអន្តរជាតិ នៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ឆ្នាំ២០១៨ ........................................................................ ៥
- ◆ ការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សហការជាមួយមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់រៀបចំវេទិកាទទួលស្វាគមន៍ក្រុមបណ្តាប្រទេសផ្តល់ជំនួយសំខាន់ៗ .......... ៩
- ◆ ការរៀបចំកម្មវិធីឧទ្ទេសនាមស្តីពីតួនាទី និងភារកិច្ចរបស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់នៅសាកលវិទ្យាល័យតាមបណ្តាខេត្តនានា........................................ ១១
  - – សកម្មភាពការងារឧទ្ទេសនាមនៅសាកលវិទ្យាល័យខេត្តសៀមរាប........................ ១២
  - – សកម្មភាពការងារឧទ្ទេសនាមនៅសាកលវិទ្យាល័យខេត្តបាត់ដំបង........................ ១៤
  - – សកម្មភាពការងារឧទ្ទេសនាមនៅសាកលវិទ្យាល័យខេត្តកំពង់ចាម........................ ១៦
  - – សកម្មភាពការងារឧទ្ទេសនាមនៅសាកលវិទ្យាល័យខេត្តតាកែវ........................ ១៨
  - – សកម្មភាពការងារឧទ្ទេសនាមនៅសាកលវិទ្យាល័យខេត្តព្រៃវែង........................ ២០
  - – សកម្មភាពការងារឧទ្ទេសនាមនៅសាកលវិទ្យាល័យខេត្តកំពត........................ ២១
- ◆ ភ្ញៀវជាតិ និងអន្តរជាតិសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ឆ្នាំ២០១៨ ........................................................................២២
- ◆ កម្មវិធីប្រគល់វិញ្ញាបនបត្រស្ម័គ្រចិត្តជូននិស្សិតដែលបំពេញការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា................................២៣
- ◆ អង្គភាពគាំពារជនរងគ្រោះរបស់អ.វ.ត.ក. បានសហការណ៍ជាមួយមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់រៀបចំវេទិកាក្រោមប្រធានបទ “កិច្ចពិភាក្សាស្តីពីការប្រកាសសាលក្រមសង្ខេប សំណុំរឿង ០០២/០២”។........................................................................២៤
- ◆ មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ សហការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួល បន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា រៀបចំកិច្ចប្រជុំធ្វើបច្ចុប្បន្នភាពកេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជា នៅព្រឹក ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨........................ ២៥
- ◆ សេចក្តីថ្លែងអំណរគុណ........................................................................ ២៦

# សេចក្តីផ្តើម

ព្រឹត្តិការណ៍ទាំងឡាយប្រព្រឹត្តទៅនៅ **មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ( **ម.ត.ឯ.ច.** ) ឆ្នាំ២០១៨ បានរៀបចំឡើងដោយមានការសហការពីដៃគូពាក់ព័ន្ធនានា រួមមាន ៖

១. ថ្នាក់ដឹកនាំទីស្តីការគណៈរដ្ឋមន្ត្រី

២. ការិយាល័យរដ្ឋបាល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាពិសេសគឺ ផ្នែកគាំពារជនរងគ្រោះ និងផ្នែកកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

៣. សហាមេធាវីជាតិ និងអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី

៤. មន្ទីរអប់រំ យុវជន និងកីឡា នៅតាមបណ្តាខេត្តនានា

៥. សាកលវិទ្យាល័យនៅតាមបណ្តារាជធានី/ខេត្ត

៦. បណ្តាអង្គការជាតិ និងអន្តរជាតិ ដែលមានការងារពាក់ព័ន្ធ

៧. ការចូលរួមពីសាធារណជនជាតិ និងអន្តរជាតិ

៨. ភ្ញៀវទស្សនកិច្ចសិក្សាជាតិ និងអន្តរជាតិ

៩. ភ្ញៀវសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិ

ការបង្កើតឱ្យមានព្រឹត្តិការណ៍ទាំងឡាយជុំវិញ មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ម.ត.ឯ.ច.) គឺដើម្បីសម្រេចគោលដៅនៃការងារជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាលើសកម្មភាពការងារអភិវឌ្ឍន៍របស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បន្ទាប់ពីបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ គឺ ៖

១. ការបញ្ជ្រាបអំពី មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(ម.ត.ឯ.ច.) ដល់សាធារណជនឱ្យយល់ដឹងជាមួយដំណើរការ និងសមិទ្ធផលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)

២. ការលើកកម្ពស់ និងរក្សាកេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

៣. ការអភិវឌ្ឍមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# សូមគោរពជូនពរជ័យ សិរីមង្គលបវរមហាប្រសើរ

**សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធក្នុងលោក**
**តាមជួយថែរក្សា និង ប្រសិទ្ធពរជ័យ**




**ក្នុងឱកាស ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបានព្រះមហាក្សត្រត្រាស់បង្គាប់តែងតាំង ជា ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងនីតិកាល ទី៦ នៃរដ្ឋសភា**

សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធទាំងឡាយក្នុងលោកសូមតាមជួយប្រោះព្រំសព្ទសាធុការពរជ័យគ្រប់ប្រការជូនចំពោះ ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សូមប្រកបដោយ សព្ទសាធុការពរ ទទួលបាននូវសុខភាពបរិបូរណ៍ បញ្ញាញាណវាងវៃ អាយុយឺនយូរ ដើម្បីរួមចំណែកដឹកនាំប្រទេសជាតិឆ្ពោះទៅរកការអភិវឌ្ឍ ប្រកបដោយសន្តិភាព និរន្តភាព និងសម្បូរសប្បាយជារៀងរហូត។

សូម ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង លោកជំទាវ ព្រមទាំងបុត្រា បុត្រី ជាទីស្រឡាញ់ ជួបតែសេចក្តីសុខ សុភមង្គល និងប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ!

**សូមគោរពជូនពរពី**
**ប្រធាន និងមន្ត្រីនៃមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់**
**ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

# វេទិកាស្ដីពី ការវិវឌ្ឍន៍នីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងសំណងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០២





ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ ម៉ោង៨:០០ ព្រឹក អង្គភាពគាំពារជនរងគ្រោះ និងអង្គភាពផ្នែកកិច្ចការសាធារណៈរបស់សាលាក្ដីខ្មែរក្រហម សហការជាមួយមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់បានរៀបចំវេទិកាស្ដីពីការវិវឌ្ឍន៍នីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងសំណងដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០២/០២។ វេទិកានេះ អញ្ជើញចូលរួមជាកិត្តិយស មានសហមេធាវីជាតិ និងអន្តរជាតិ ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២/០២ ចំនួន១១៥នាក់ ដែលមកពីបណ្ដាខេត្ត និងរាជធានី ដូចជា រាជធានីភ្នំពេញ កណ្ដាល កំពង់ស្ពឺ កំពង់ឆ្នាំង និងតាកែវ។

*គោលបំណងនៃការរៀបចំកម្មវិធីនេះ មានដូចតទៅ ៖*

១. ផ្សព្វផ្សាយអំពីការវិវឌ្ឍន៍នីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងសំណងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០២ ដល់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២/០២។



២. ការយកចិត្តទុកដាក់ចំពោះសុខទុក្ខ ការលើកទឹកចិត្ត ការផ្តល់កម្លាំងចិត្ត ការជួយសម្រាលអារម្មណ៍ឈឺចាប់ដែលទទួលរងពីអតីតកាលក្នុងរបបខ្មែរក្រហម និងការផ្តល់ក្តីកក់ក្តៅលើកស្មារតីឱ្យឈប់មានការ ភ័យខ្លាចត្រូវហ៊ាននិយាយការពិត ចំពោះការដែលមកចូលរួមធ្វើសក្ខីកម្មនៅក្នុងសវនាការរបស់អង្គជំនុំជម្រះកាត់ក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម។





៣. ពន្យល់អំពីអត្ថន័យនៃសាលក្រម០០២/០១ និង០០២/០២។

៤. ការរំឭកអំពីការឈឺចាប់ ទុក្ខវេទនារបស់ជនរងគ្រោះ តាមរយៈការបញ្ចាំងវីដេអូ ស្តីពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ទុក្ខលំបាករបស់ស្ត្រីនៅការដ្ឋានការងារ ១មករា ខេត្តកំពង់ធំ ទុក្ខវេទនារបស់ជនជាតិចាម និងវៀតណាម ការបង្ខំឱ្យប្តេជ្ញាចិត្តយកគ្នាជាប្តីប្រពន្ធ និងការបង្ខំឱ្យរួមដំណេក។





៥. បង្ហាញអំពីសម្បជញ្ញៈរបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម តាមរយៈការបញ្ចាំងវីដេអូស្តីពី ខៀវ សំផន សំពះសុំទោសចំពោះជនរងគ្រោះក្នុងរបបខ្មែរក្រហម និងគោរពវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ដោយសារសោកនាដកម្មក្នុងពេលនោះ។

៦. បង្ហាញអំពីអត្ថប្រយោជន៍នៃការចំណាយពេលយូររបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងដំណើរការកាត់ក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម។

៧. បង្ហាញអំពីទំហំផលប្រយោជន៍ និងអត្ថន័យនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

៨. ពន្យល់អំពីគោលបំណងនៃការបង្កើតអ.វ.ត.ក.។

៩. ពន្យល់អំពីអត្ថន័យនៃសំណង ចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងបង្ហាញគម្រោងសំណងដែលបានអនុវត្តរួចហើយ។

# ទស្សនកិច្ចសិក្សារបស់ភ្ញៀវជាតិ និងអន្តរជាតិ នៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ឆ្នាំ២០១៨



**ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨** ម.ត.ឯ.ច. បានធ្វើបដិសណ្ឋារកិច្ចចំពោះក្រុម ទស្សនកិច្ចសិក្សាចំនួន ១៤នាក់ មកពីសាកលវិទ្យាល័យមហាផ្ទៃហាណូយនៃប្រទេសវៀតណាមដែលមានគោលបំណង ទស្សនកិច្ច និងផ្លាស់ប្តូរបទពិសោធន៍ការងារផ្នែកតម្កល់ឯកសារ។



**ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨** ម.ត.ឯ.ច. បានរៀបចំកម្មវិធីទទួលសិស្សានុសិស្សមកពីវិទ្យា ល័យវត្តកោះ ចំនួន១១៤នាក់ ដើម្បីធ្វើទស្សនកិច្ចសិក្សាស្វែងយល់អំពីមជ្ឈមណ្ឌលដែលជាកេរដំណែលរបស់អ.វ.ត.ក.។





**ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១៨** ម.ត.ឯ.ច. បានរៀបចំទទួលស្វាគមន៍ ក្រុមការងារនៃកម្មវិធីសច្ចធម៌ប្រវត្តិសាស្ត្រ ដែលបានដឹកនាំលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មកពីវិទ្យាល័យ ប៊ុនរ៉ានីហ៊ុនសែនវត្តភ្នំ និងនិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញសរុបចំនួន ២១៧នាក់ ដើម្បីផ្តល់ការស្វែងយល់អំពីដំណើរការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម និងធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ផងដែរ។



**ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨** ម.ត.ឯ.ច. បានធ្វើគារវកិច្ច ក្រុមចៅក្រមតុលាការកំពូលនៃប្រទេសបង់ក្លាដែសចំនួន០៣រូប ដែលមកធ្វើទស្សនកិច្ចសិក្សានៅម.ត.ឯ.ច. ក្នុងគោលបំណងដើម្បីស្វែងយល់អំពីយន្តការនៃសាលាក្តីខ្មែរក្រហម និងជាការផ្លាស់ប្តូរបទពិសោធន៍ នៃរឿងរ៉ាវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រល័យពូជសាសន៍ រវាងតុលាការឧក្រិដ្ឋកម្មនៃប្រទេសទាំងពីរ។



**ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨** ម.ត.ឯ.ច. បានរៀបចំទទួលស្វាគមន៍ និងធ្វើបទបង្ហាញអំពីតួនាទី និងភារកិច្ចរបស់ម.ត.ឯ.ច. ជូនក្រុមការងារកម្មវិធីសច្ចធម៌ប្រវត្តិសាស្ត្រ ដែលបានដឹកនាំនិស្សិតឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣ ចំនួន២៥៥នាក់ មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីធ្វើទស្សនកិច្ចសិក្សានៅម.ត.ឯ.ច.។



**ថ្ងៃ០៨ ខែឧសភា ឆ្នាំ២០១៨** ម.ត.ឯ.ច. បានរៀបចំទទួលស្វាគមន៍ និងធ្វើបទបង្ហាញអំពីម.ត.ឯ.ច. ជូនក្រុមការងារកម្មវិធីសច្ចធម៌ ប្រវត្តិសាស្ត្រដែលបានដឹកនាំនិស្សិតចំនួន២៦៦នាក់ មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីធ្វើទស្សនកិច្ចសិក្សា។



**ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨** ម.ត.ឯ.ច. បានទទួលស្វាគមន៍ សាស្ត្រាចារ្យបណ្ឌិតផ្នែកច្បាប់ Kunihiko Yoshida មកពីសាកលវិទ្យាល័យ Hokkaido ប្រទេសជប៉ុន លោកស្រីសាស្ត្រាចារ្យ Kasumi Nakagawa មកពីសាកលវិទ្យាល័យបញ្ញាសាស្ត្រ កម្ពុជា និងនិស្សិតថ្នាក់បណ្ឌិត មកពីសាកលវិទ្យាល័យ York ចក្រភពអង់គ្លេស កញ្ញា Eliana Hysollau។



**ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៨** ម.ត.ឯ.ច. សហការជាមួយផ្នែកកិច្ចការសាធារណៈ នៃសាលាក្តីខ្មែរក្រហម និងក្រុមកម្មវិធីសច្ចធម៌ប្រវត្តិសាស្ត្រ បានរៀបចំកម្មវិធីទស្សនកិច្ចសិក្សាជូនគរុសិស្ស នៃវិទ្យាស្ថានជាតិអប់រំ សរុបចំនួន២៤០នាក់នៅសាលឈូកសនៃម.ត.ឯ.ច.។





**ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨** ម.ត.ឯ.ច. សហការ ជាមួយផ្នែកកិច្ចការសាធារណៈនៃសាលាក្តីខ្មែរក្រហម និងក្រុមកម្មវិធីសច្ចធម៌ប្រវត្តិសាស្ត្របាន រៀបចំកម្មវិធីដើម្បីទទួលទស្សនកិច្ច សិក្សារបស់គរុនិស្សិតនៃវិទ្យាស្ថានជាតិអប់រំ សរុបចំនួន១៦៦នាក់ នៅម.ត.ឯ.ច.។





**ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១៨** ក្រោមកិច្ចសហការជាមួយនឹងសារមន្ទីរទួលស្លែង បានដឹកនាំនិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ចំនួន ២០នាក់ ចុះទស្សនកិច្ចនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់។



**ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨** មានការចុះទស្សនកិច្ចរបស់មន្ត្រីបម្រើការងារ នៅអង្គការសហប្រជាជាតិមកកាន់ មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ចំនួន២រូប។





នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឯកឧត្តម កែវ រ៉េមី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទទួលបន្ទុកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងជាអនុប្រធានអចិន្ត្រៃយ៍នៃក្រុមការងាររាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកសាលាក្តីខ្មែរក្រហម និងឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានជួបពិភាក្សាការងារជាមួយ លោកស្រី ហ្វីការ៉ា ណាឌីយ៉ា មន្ត្រីសារមន្ទីរនៃការចងចាំហូឡូកូសសហរដ្ឋអាមេរិក។ ជំនួបពិភាក្សាដែលបានធ្វើឡើងរវាងភាគីទាំងពីរ ដើម្បីផ្តោតជាសំខាន់លើការពង្រឹងកិច្ចសហប្រតិបត្តិការ រវាងមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ និងសារមន្ទីរហូឡូកូស ក៏ដូចជាដើម្បីត្រៀមរៀបចំដំណើរទស្សនកិច្ច របស់នាយកសារមន្ទីរហូឡូកូស និងមន្ត្រីជាន់ខ្ពស់ជាច្រើនរូបទៀតនៅក្នុងអំឡុងឆ្នាំ២០១៩ខាងមុខ។

# ការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សហការជាមួយមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ រៀបចំវេទិកាទទួលស្វាគមន៍ក្រុមបណ្ដាប្រទេសផ្ដល់ជំនួយសំខាន់ៗ







**ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៨** ការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា សហការជាមួយ មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់បានរៀបចំវេទិកាទទួលស្វាគមន៍ ក្រុមបណ្ដាប្រទេសផ្ដល់ជំនួយសំខាន់ៗ (Principal Donors Group-PDG) សម្ដែងការគួរសមក្នុងវេទិកានេះ និងរៀបរាប់ ស្ដីពីវឌ្ឍនភាពការងារ និងសមិទ្ធិផលសម្រេចបានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)។ ដែលទទួលបន្ទុកការងាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក.)ប្រចាំនៅអង្គការសហប្រជាជាតិ (អ.ស.ប.) ទីក្រុងញូវយ៉ក សហរដ្ឋ អាមេរិករួមមានសមាសភាព១០ប្រទេសគឺ អូស្ត្រាលី បារាំង អាល្លឺម៉ង់ ជប៉ុន ស៊ុយអ៊ែត ហ្វាំងឡង់ ណ័រវេស អង់គ្លេស អាមេរិក កូរ៉េខាងត្បូង និងសហភាពអឺរ៉ុប ក្នុងឱកាសនេះក៏មានការចូលរួមផងដែរពីសំណាក់លោក David Scheffer



អ្នកជំនាញកាពិសេស របស់លោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិដើម្បីចូលសម្តែងការគួរសមក្នុងវេទិកានេះ និងរៀបរាប់ស្តីពីវឌ្ឍនភាពការងារ និងសមិទ្ធផលសម្រេចបាន របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)។





# ការរៀបចំកម្មវិធី ឧទ្ទេសនាមស្តីពីតួនាទី និងភារកិច្ចរបស់ ម.ត.ឯ.ច. នៅសាកលវិទ្យាល័យតាមបណ្តាខេត្តនានា

ការធ្វើកម្មវិធីនេះ ត្រូវបានអនុញ្ញាតជាគោលការណ៍ពីឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ស្របតាមអនុក្រឹត្យលេខ១៥៩ អនក្រ.បក របស់រាជរដ្ឋាភិបាលកម្ពុជា និងមានការជួយសម្រួលការងាររដ្ឋបាលពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ព្រមទាំងទទួលបានការសហការយ៉ាងល្អពីថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកសិក្សានៃសាកលវិទ្យាល័យនៅតាមបណ្តាខេត្តនានា នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូផងដែរ។

គោលបំណងនៃការរៀបចំកម្មវិធីនេះ គឺជាការផ្សព្វផ្សាយជំហានទី២ សម្រាប់ឆ្នាំ២០១៨ ចាំបាច់ឱ្យនិស្សិត លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យ នៅតាមបណ្តាខេត្តបានជ្រាបបានយល់ និងបានដឹងអំពីមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានបណ្ណាល័យអេឡិចត្រូនិក (e-library) និងសាលាក្តីទូរនិម្មិត (VirtualTribunal V.T) ដែលអាចបម្រើការស្រាវជ្រាវជូនសាធារណជនទូទៅជាតិ និងអន្តរជាតិ ក្នុងខណៈដែល មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធ នឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទើបបង្កើតដែលមានលក្ខណៈជាបណ្ណសារដ្ឋានជំនាញ គឺតម្កល់នូវសំណុំឯកសារច្បាប់ និងឯកសារពាក់ព័ន្ធនានា ជាឯកសាររឹង និងឯកសារទន់ ដែលបានមកពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ទន្ទឹមនឹងនេះដែរ ជាការផ្សព្វផ្សាយដើម្បីឱ្យជ្រាបថា មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បង្កើតឡើងក្នុងន័យរក្សាកេរដំណែលនិងជាទីកន្លែងផ្សព្វផ្សាយអំពីដំណើរការ និងសមិទ្ធផលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រមទាំងបញ្ជ្រាបនូវប្រវត្តិសាស្ត្រខ្មែរក្រហម ការចងចាំ ការអប់រំ និងការទប់ស្កាត់មិនឱ្យវិលត្រឡប់មកវិញ នៃរបបសម្លាប់រង្គាល និងប្រល័យពូជសាសន៍។



**លោកស្រី កែវ សុនី** អនុប្រធាន ម.ត.ឯ.ច. និងជាប្រធានក្រុមការងារ បានដឹកនាំធ្វើសកម្មភាពឧទ្ទេសនាម។ បណ្តាសាកលវិទ្យាល័យដែលបានសហការរៀបចំកម្មវិធីឧទ្ទេសនាមរួមមាន ៖





១. សាកលវិទ្យាល័យបៀលប្រាយ (សាខាខេត្តសៀមរាប) នៅថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៨ មានការអញ្ជើញចូលរួមស្វាគមន៍ពីលោក ស៊ីវ វុទ្ធី សាកលវិទ្យាធិការនៃសាកលវិទ្យាល័យបៀលប្រាយ (សាខាសៀមរាប) និងមាននិស្សិតចូលរួមចំនួន១៥០នាក់។

២. សាកលវិទ្យាល័យបញ្ញាសាស្ត្រ (សាខាខេត្តសៀមរាប) នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ មានការអញ្ជើញចូលរួមស្វាគមន៍ពីលោក ពេជ្រ កុសល ប្រធានការិយាល័យអប់រំអន្តរជាតិ តំណាងឱ្យសាកលវិទ្យាធិការនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងមាននិស្សិតចូលរួមចំនួន៥០នាក់។





៣. សាកលវិទ្យាល័យសៅស៍អ៊ីសច៍អេយសៀខេត្តសៀមរាបថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨ មានការអញ្ជើញចូលរួមស្វាគមន៍ពីសាកលវិទ្យាធិការរង បណ្ឌិត មាន សុធី តំណាងឱ្យសាកលវិទ្យាធិការនៃសាកលវិទ្យាល័យសៅស៍អ៊ីសច៍អេយសៀ និងមាននិស្សិតចូលរួមចំនួន៥៨នាក់។



៤. សាកលវិទ្យាល័យឯកទេសនៃកម្ពុជា (សាខាខេត្តសៀមរាប) នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៨ មានការអញ្ជើញចូលរួមស្វាគមន៍ពីលោក ម៉ម ប៊ុណ្ណារា ប្រធានផ្នែករដ្ឋបាលនៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជាមាន និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បរិញ្ញាបត្រចូលរួម ចំនួន១០៣នាក់។



៥.នៅសាកលវិទ្យាល័យមេគង្គកម្ពុជា(សាខាខេត្តសៀមរាប)ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៨ មានការចូលរួមស្វាគមន៍ពីលោក ណូ ចាន់ណារ៉ា នាយក រងសាខានៃសាកលវិទ្យាល័យមេគង្គកម្ពុជា និងមាននិស្សិតចូលរួមចំនួន៥០នាក់។

# សកម្មភាពការងារឧទ្ទេសនាមស្តីពីមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ នៅតាមបណ្តាសាកលវិទ្យាល័យខេត្តបាត់ដំបង

## សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សាខាខេត្តបាត់ដំបង

ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ លោក ធួក ជាងលី អនុប្រធានមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានដឹកនាំក្រុមការងាររបស់ម.ត.ឯ.ច. សហការរៀបចំកម្មវិធីឧទ្ទេសនាមស្តីពីតួនាទី និងភារកិច្ចរបស់ម.ត.ឯ.ច. ជាមួយសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សាខាខេត្តបាត់ដំបង។ លោក ណុល សុខុន នាយករងនៃសាកលវិទ្យាល័យបានស្វាគមន៍ និងមាននិស្សិតចូលរួមចំនួន៦៥នាក់។




## សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច សាខាខេត្តបាត់ដំបង

ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច សាខាខេត្តបាត់ដំបងបានទទួលសហការរៀបចំកម្មវិធីធ្វើបទបង្ហាញដោយមន្ត្រីជំនាញ ដែលមានខ្លឹមសារជុំវិញ ម.ត.ឯ.ច.។ កម្មវិធីនេះត្រូវបានទទួលស្វាគមន៍ដោយលោក ឆេង ឈុនលី ប្រធានការិយាល័យរដ្ឋបាល និងសិក្សានៃសាកលវិទ្យាល័យ និងមាននិស្សិតចូលរួមចំនួន១០០នាក់។




## សាកលវិទ្យាល័យបៀលប្រាយ សាខាខេត្តបាត់ដំបង



ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ លោកស្រីជា សារ៉ុន ប្រធានម.ត.ឯ.ច. និងលោកគ្រូ សុង សៀង ប្រធានការិយាល័យសិក្សា ជាតំណាងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យបៀលប្រាយ សាខាខេត្តបាត់ដំបង បានសហការរៀបចំធ្វើកម្មវិធីឧទ្ទេសនាមស្ដីពីតួនាទី និងភារកិច្ចរបស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ មាននិស្សិតចូលរួមចំនួន១៥២នាក់។

## សាកលវិទ្យាល័យបាត់ដំបង

ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ លោកស្រីជា សារ៉ុន ប្រធានម.ត.ឯ.ច. និងលោក ប៊ិន ឈុំ សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យបាត់ដំបង សាខាខេត្តបាត់ដំបង បានសហការរៀបចំធ្វើកម្មវិធីឧទ្ទេសនាមស្ដីពីតួនាទី និងភារកិច្ចរបស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់មាននិស្សិតចូលរួមចំនួន១៥៤នាក់។





## មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តបាត់ដំបង

ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ លោកស្រីប្រធានមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់បានដឹកនាំមន្ត្រីចុះធ្វើបទបង្ហាញស្ដីពីតួនាទី និងភារកិច្ចរបស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តបាត់ដំបង។ ក្នុងកម្មវិធីនេះត្រូវបានទទួលស្វាគមន៍ពីលោកនាយករង និងមានគរុសិស្សចូលរួមចំនួន១៥៨នាក់។





លោកស្រី **ខា សាខ៊ុន** ប្រធាន ម.ត.ឯ.ច. បានដឹកនាំក្រុមការងារធ្វើសកម្មភាពឧទ្ទេសនាម

សហការរៀបចំកម្មវិធីគឺ៖

**មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម**



១.មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ មាន គរុសិស្សចូលរួមចំនួន១៣៩នាក់។



**សាកលវិទ្យាល័យវេស្ទើនសាខាខេត្តកំពង់ចាម**



២. សាកលវិទ្យាល័យវេស្ទើនសាខាខេត្តកំពង់ចាម នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ មាននិស្សិតចូលរួមចំនួន១៣៣នាក់។



**សាកលវិទ្យាល័យជាស៊ីមកំចាយមារសាខាខេត្តកំពង់ចាម**



៣. សាកលវិទ្យាល័យ ជាស៊ីមកំចាយមារសាខាខេត្ត កំពង់ចាម នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ មាននិស្សិតចូលរួមចំនួន១២៤នាក់។



សាកលវិទ្យាល័យឯកទេសនៃកម្ពុជា សាខា ខេត្តកំពង់ចាម

លោក **ឆួក ឆាឧលី** អនុប្រធាន ម.ត.ឯ.ច. បានដឹកនាំក្រុមការងារធ្វើសកម្មភាពឧទ្ទេសនាម ដោយមានការសហការរៀបចំកម្មវិធីគឺៈ

១. សាកលវិទ្យាល័យឯកទេសនៃកម្ពុជា សាខា ខេត្តកំពង់ចាម នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៨ លោក ហែម បញ្ញា នាយកសាខាទទួលស្វាគមន៍ និង មាននិស្សិតចូលរួមចំនួន៧៥នាក់។






មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម



២. មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ លោក សេង ស៊ីម នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាមទទួលស្វាគមន៍ និងមានគរុសិស្សចូលរួមចំនួន១៥០នាក់។





# សកម្មភាពការងារឧទ្ទេសនាមស្តីពី ម.ត.ឯ.ច. នៅបណ្តាសាកលវិទ្យាល័យ ខេត្តតាកែវ

សាកលវិទ្យាល័យអង្គរខេមរា ខេត្តតាកែវ



លោកស្រី **ជា សាវ៉ុន** ប្រធាន ម.ត.ឯ.ច. ដឹកនាំក្រុមការងារដែលមានសមាសភាព ជាមន្ត្រីជំនាញសម្រាប់ ធ្វើបទបង្ហាញជុំវិញខ្លឹមសារ ដែលពាក់ព័ន្ធនឹង ម.ត.ឯ.ច.កម្មវិធីនេះមានការសហការរៀបចំកម្មវិធីគឺៈ

១. សាកលវិទ្យាល័យអង្គរខេមរា ខេត្តតាកែវ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ មាននិស្សិតចូលរួម ៤៧នាក់។





សាលាគរុកោសល្យភូមិភាគ និងវិក្រឹត្យការខេត្តតាកែវ



២. សាលាគរុកោសល្យភូមិភាគ និងវិក្រឹត្យការ ខេត្តតាកែវ នៅថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៨ មានគរុសិស្សចូលរួម ១៩៨នាក់។





## សាកលវិទ្យាល័យបៀលប្រាយ សាខាខេត្តតាកែវ



លោក **ធូក ឆាងលី** អនុប្រធានម.ត.ឯ.ច. បានដឹកនាំក្រុមការងារធ្វើសកម្មភាពឧទ្ទេសនាម ដោយមានការសហការរៀបចំកម្មវិធីគឺ ៖

១. សាកលវិទ្យាល័យបៀលប្រាយ សាខាខេត្តតាកែវ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨ មាននិស្សិតចូលរួមចំនួន៥៥នាក់។





## សាកលវិទ្យាល័យអង្គរខេមរា ខេត្តតាកែវ



២. សាកលវិទ្យាល័យអង្គរខេមរា ខេត្តតាកែវ នៅថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៨ មាននិស្សិតចូលរួមចំនួន ៥២នាក់។





## សកម្មភាពការងារឧទ្ទេសនាមស្តីពី ម.ត.ឯ.ច. នៅបណ្ណាសាកលវិទ្យាល័យ ខេត្តព្រៃវែង

### សាកលវិទ្យាល័យជាស៊ីមកំចាយមារ សាខាខេត្តព្រៃវែង

លោកស្រី **ជា សាវ៉ុន** ប្រធាន ម.ត.ឯ.ច. ដឹកនាំក្រុមការងារដែលមានសមាសភាពជាមន្រ្តីជំនាញសម្រាប់ធ្វើបទបង្ហាញជុំវិញខ្លឹមសារដែលពាក់ព័ន្ធនឹងម.ត.ឯ.ច. បានចុះធ្វើសកម្មភាពឧទ្ទេសនាមនៅតាមបណ្តាសាកលវិទ្យាល័យខេត្តព្រៃវែង កម្មវិធីនេះមានការសហការរៀបចំកម្មវិធីគឺ ៖

១. សាកលវិទ្យាល័យជាស៊ីមកំចាយមារ សាខាខេត្តព្រៃវែង នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៨ មាននិស្សិតចូលរួមចំនួន១២៥នាក់។





### វិទ្យាស្ថានក្រុងអង្គរ សាខាខេត្តព្រៃវែង





២. វិទ្យាស្ថានក្រុងអង្គរ សាខាខេត្តព្រៃវែង នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៨ មាននិស្សិតចូលរួមចំនួន៧៥នាក់។



# សកម្មភាពការងារឧទ្ទេសនាមស្តីពី ម.ត.ឯ.ច. នៅបណ្តាសាកលវិទ្យាល័យ ខេត្តកំពត

សាកលវិទ្យាល័យឯកទេសនៃកម្ពុជា សាខាខេត្តកំពត





លោក **ឆ្ងួក ឆាចលី** អនុប្រធាន ម.ត.ឯ.ច. ដឹកនាំក្រុមការងារដែលមានសមាសភាព ជាមន្ត្រីជំនាញសម្រាប់ធ្វើបទបង្ហាញស្តីពីខ្លឹមសារជុំវិញម.ត.ឯ.ច. បានចុះធ្វើបទឧទ្ទេសនាម នៅតាមបណ្តាសាកលវិទ្យាល័យខេត្តកំពត កម្មវិធីនេះត្រូវបានរៀបចំ និងសហការ ដោយ ៖

១. សាកលវិទ្យាល័យឯកទេសនៃកម្ពុជា សាខាខេត្តកំពត នៅព្រឹកថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៨ មាននិស្សិតចូលរួម១០០នាក់។



សាកលវិទ្យាល័យឯកទេសនៃកម្ពុជា សាខាខេត្តកំពត



២. សាកលវិទ្យាល័យអង្គរខេមរា សាខាខេត្តកំពត នៅពេលរសៀល ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៨ មាននិស្សិតចូលរួមចំនួន៩០នាក់។



# ភ្ញៀវជាតិ និងអន្តរជាតិសិក្សាស្រាវជ្រាវនៅ ម.ត.ឯ.ច. ឆ្នាំ២០១៨

ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ និស្សិតមកពីវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រចំនួន០៤នាក់ បានមកសិក្សាស្រាវជ្រាវ ឯកសារពាក់ព័ន្ធនឹងសំណុំរឿង ០០១ ករណី កាំង ហ្គេចអ៊ាវ ហៅឌុច នៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។



ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ បណ្ឌិត Robyn Holder មកពីសាកលវិទ្យាល័យ Griffith ប្រទេសអូស្ត្រាលី មកធ្វើការស្រាវជ្រាវលើប្រធានបទ Civil Party Participation រយៈពេល០២ សប្តាហ៍។



ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៨ លោកស្រីសាស្ត្រាចារ្យ Jennifer Rasmussen, នាយិកានៃមជ្ឈមណ្ឌល Strategic partnerships with the Center for Justice and Accountability (CJA) សហរដ្ឋអាមេរិក និងភ្ញៀវសិក្សាស្រាវជ្រាវ មកពីប្រទេសបារាំងចំនួន៣នាក់។





# កម្មវិធីប្រគល់វិញ្ញាបនបត្រស្ម័គ្រចិត្ត
# ជូននិស្សិតដែលបំពេញការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលតម្កល់
# ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

និស្សិតស្ម័គ្រចិត្តចំនួន១៨នាក់ មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ១៥នាក់ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច០៣នាក់ បានទទួលវិញ្ញាបនបត្រស្ម័គ្រចិត្តពីមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ដោយបានបំពេញការងាររយៈពេល១២០ម៉ោង ជាមួយមន្រ្តីជំនាញនៃមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមផ្នែកនីមួយៗ គឺមានផ្នែកតម្កល់ឯកសារ និងបណ្ណាល័យ ផ្នែកទំនាក់ទំនងរដ្ឋបាល ផ្នែកព័ត៌មានវិទ្យា និងផ្នែកកិច្ចការសាធារណៈ លើការងាររួមមាន ការធ្វើ Video Alignments, Transcript ការថតចម្លងការសែត ទស្សនាវដ្តី និងការរៀបចំសៀវភៅឡើងវិញតាមប្រភព ប្រភេទ កាលបរិច្ឆេទបោះពុម្ព អ្នកផលិត។ល។

ជាមួយនឹងការបំពេញការងារស្ម័គ្រចិត្តនេះ និស្សិតបានទទួលការចែករំលែកចំណេះដឹងបទពិសោធន៍ពីមន្រ្តីជំនាញនៃមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមផ្នែកនីមួយៗ ដើម្បីមានសមត្ថភាពបន្ថែមទៀតក្នុងការចាប់យកឱកាសការងារដ៏ខ្លីខាងមុខ។



# កិច្ចពិភាក្សាស្ដីពីការប្រកាសសាលក្រម សង្ខេបសំណុំរឿង ០០២/០២



ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គភាពគាំពារជនរងគ្រោះនៃអ.វ.ត.ក. បានសហការជាមួយមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ដើម្បីផ្ដល់ទីកន្លែងរៀបចំវេទិកាក្រោមប្រធានបទ ដែលមានខ្លឹមសារ ៖

១. ការដាក់បញ្ចាំងវីដេអូ ពាក់ព័ន្ធនឹងការប្រឈមមុខនឹងយុត្តិធម៌

២. ការធ្វើបទបង្ហាញទាក់ទងនឹងសាលក្រមក្នុងករណី ០០២/០២

៣. ការធ្វើបទបង្ហាញ និងកិច្ចពិភាក្សាដែលទាក់ទងនឹងការកសាងសន្តិភាព និងការផ្សះផ្សា



# មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ សហការជាមួយ ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា រៀបចំកិច្ចប្រជុំធ្វើបច្ចុប្បន្នភាពកេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅព្រឹក ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨

គោលបំណងនៃកិច្ចប្រជុំនេះ ដើម្បីផ្ដល់ឱកាសក្នុងការចែករំលែកព័ត៌មាន កិច្ចសហការ និងការសម្របសម្រួលដែលកំពុងដំណើរការរវាងដៃគូពាក់ព័ន្ធផ្សេងៗ ដែលកំពុងបំពេញការងារពាក់ព័ន្ធកម្មវិធី កេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) សមាសភាពចូលរួមមាន ៖ មន្ត្រីជាន់ខ្ពស់ថ្នាក់ជាតិ និងអន្តរជាតិរបស់អ.វ.ត.ក. តុលាការជាតិ តំណាងក្រសួងយុត្តិធម៌ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ តំណាងស្ថានទូតនានា អ្នកសិក្សាជាន់ខ្ពស់ អ្នកជំនាញផ្នែកច្បាប់ និងអង្គការសង្គមស៊ីវិល។









# សេចក្ដីថ្លែងអំណរគុណ

**មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** មានកិត្តិយសខ្ពង់ខ្ពស់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

១. ថ្នាក់ដឹកនាំទីស្ដីការគណៈរដ្ឋមន្ត្រី

២. ការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

៣. អង្គភាពគាំពារជនរងគ្រោះ និងអងង្គភាពផ្នែកកិច្ចការសាធារណៈ

៤. សហាមេធាវីជាតិ និងអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

៥. មន្ទីរអប់រំ យុវជន និងកីឡា នៅតាមបណ្ដាខេត្តនានា

៦. សាកលវិទ្យាល័យ និងវិទ្យាល័យនានា នៅតាមបណ្ដារាជធានី/ខេត្ត

៧. បណ្ដាអង្គការជាតិ និងអន្តរជាតិ ដែលមានការងារពាក់ព័ន្ធ

៨. ការចូលរួមពីសាធារណជនជាតិ និងអន្តរជាតិ

៨. ភ្ញៀវទេសចរនកិច្ចសិក្សាជាតិ និងអន្តរជាតិ

១០. ភ្ញៀវសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិ ដែលបានលះបង់កម្លាំងកាយចិត្ត និងពេលវេលាដ៏មានតម្លៃជួយផ្ដល់អនុសាសន៍ និងចូលរួមជាមួយកម្មវិធី និងវេទិកាទាំងឡាយនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីសម្រេចគោលដៅនៃការងារជាយុទ្ធសាស្ត្រ លើសកម្មភាពការងារអភិវឌ្ឍន៍របស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងការលើកកម្ពស់ និងរក្សាកេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**សូមគោរពជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការ ភ្ញៀវកិត្តិយសជាតិ លោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្ស និងគរុសិស្ស ព្រមទាំងឯកឧត្តមឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូតប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងភ្ញៀវអន្តរជាតិ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។**



# ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗនៃ អ.វ.ត.ក.

# Principal Donors Group-PDG



